*រាជធានីភ្នំពេញ; ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ១៩៩៤*

**អនុក្រឹត្យ លេខ ៥៧**

**ស្តីពីការផ្តល់សិទ្ធិចុះហត្ថលេខាលើ ប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អាគារ ក្នុងរាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសេចក្តីត្រូវការចាំបាច់

**សំរេច**

មាត្រា ១ : ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ជាអ្នកមានសិទ្ធិ ចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរអាជ្ញាប័ណ្ណសាងសង់អាគារគ្រប់ផ្នែក ក្នុងរាជធានីភ្នំពេញ ។

មាត្រា ២ : ក្នុងករណីអវត្តមាន ឯកឧត្តមប្រតិភូត្រូវផ្ទេរសិទ្ធិ ជូនអភិបាលរងម្នាក់ ដើម្បីចុះហត្ថលេខាជំនួស ។

មាត្រា ៣ : រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន ពាក់ព័ន្ធនិងប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |